# ប្រវត្តិជំនឿ និងអានិសង្សបិណ្ឌ

សង្គមខ្មែរចាត់ទុកភ្ជុំបិណ្ឌជាទំនៀមបុណ្យប្រពៃណីដ៏សំខាន់ដូចបណ្ដាពិធីឯទៀតនៃទ្វាទសមាស។ ដើមហេតុនៃភ្ជុំបិណ្ឌនេះ បើមើលប្រភពភស្តុតាងប្រវត្តិសាស្ត្រតាមរយៈសិលាចារឹកសម័យកណ្ដាល (IMA.3) ឃើញថានៅក្នុងសតវត្សរ៍ទី១៦ ព្រះបាទជេដ្ឋាទី១ (១៥៧៦-១៥៩៤)ទ្រង់បានប្រារព្ធ"ពិធីតប៌្បណទ្វាទសបិណ្ឌ" ដើម្បីឧទ្ទិសកុសលនៅអំឡុងបុណ្យដាក់បិណ្ឌទាំង១២។[1] ប៉ុន្តែបើមើលភស្តុតាងប្រវត្តិសាស្ត្រហួសទៅដល់សម័យអង្គរ អ្នកស្រាវជ្រាវយល់ថា ពិធីភ្ជុំបិណ្ឌទទួលឥទ្ធិពលពិធីស្រាទ្ធ *[śrāddha]* (ស្រាទ្ធ) នៃវប្បធម៌ឥណ្ឌា។[2] ពាក្យស្រាទ្ធឃើញក្នុងសិលាចារឹកថ្នល់បារាយណ៍ *(K.279c)* ចារក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១(៨៨៩-៩០០) ដែលមានសេចក្ដីរៀបរាប់ពិធីបោះបាយបិណ្ឌឧទ្ទិសដល់អ្នកស្លាប់អនាថា ឬស្លាប់ក្នុងសមរភូមិ ដើម្បីអាចចាប់ជាតិកំណើតថ្មីបាន។ ឯរូបសត្វនរកក៏ឃើញមានឆ្លាក់ច្បាស់នៅអង្គរវត្ត និងប្រាសាទតានៃ (រូបលេខ១)។

ទោះយ៉ាងណាក្ដី សព្វថ្ងៃមនុស្សខ្មែរណាម្នាក់ក៏យល់ដូចគ្នាថា ភ្ជុំបិណ្ឌគឺជាទំនៀមក្នុងព្រះពុទ្ធសាសនាដែរ។ ហេតុពោលដូច្នោះក៏មិនខុស ដ្បិតតាំងពីដូនតាមកខ្មែរតែងប្រារព្ធភ្ជុំបិណ្ឌនៅតាមវត្តអារាមជាដរាប។ មិនតែប៉ុណ្ណោះ ពាក់ព័ន្ធនឹងប្រវត្តិភ្ជុំបិណ្ឌ ក៏មានរឿងដែលព្រះសង្ឃតែងតែលើកមកទេសនាបញ្ជាក់ជារឿយៗពីក្នុងគម្ពីរបេតវត្ថុ គម្ពីរធម្មបទដ្ឋកថា សាស្ត្រាវិជ្ជាធរ ឬព្រះនេមិរាជជាតក និងព្រះមហាល័យសូត្រជាដើម។ លើសពីនេះក្នុងគម្ពីរ ឬរឿងរ៉ាវខាងលើឱ្យដឹងថា ភ្ជុំបិណ្ឌកើតដោយព្រះអរិយបុគ្គលមានឥទ្ធិរិទ្ធដូចជាព្រះពុទ្ធ ព្រះមោគ្គលាន ព្រះមាល័យ ឬព្រះនេមិរាជ... បានឃើញសេចក្ដីទុក្ខវេទនារបស់ពពួកសត្វនរកប្រេត ដែលយមបាលធ្វើទុក្ខទោស ហើយពពួកសត្វនរកប្រេតទាំងឡាយនោះតែងប្រាថ្នាឱ្យញាតិសន្តានធ្វើបុណ្យឧទ្ទិសកុសលឱ្យ (រូបលេខ២)។[3]

---

[1] វង់ សុជាវ៉ា, ២០១២, ទំ.១១៦

[2] បទបង្ហាញអំពី ពីពិធី "ស្រាទ្ធ" របស់ឥណ្ឌាមកបុណ្យ "ភ្ជុំបិណ្ឌ" ដោយលោក ស៊ីយ៉ុន សុភារិទ្ធ រៀបចំដោយអង្គការយសោធរ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧។ ពាក្យស្រាទ្ធ គេឃើញលេចឡើងក្នុងសិលាចារឹកចាប់ពីរវាងចុងសតវត្សទី៩ ដូចជា K.279c, K.262, K.669, K.220 និង IMA-3 ជាដើម។

[3] ឱម ណារត្រី (ឆ្នាំ?): អារម្ភកថា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១ ការធ្វើទារុណកម្មសត្វនរកនៅលើ ចម្លាក់ជញ្ជាំងខាងត្បូងប្រាសាទអង្គរវត្ត



រូបលេខ២ ព្រះបាទនេមិរាជយាងទត ការធ្វើទារុណកម្មសត្វនរកនៅលើស្ថាននរក

ជាការពិត "ភ្ជុំបិណ្ឌ" គឺមាន "បាយបិណ្ឌ" ជារណ្ដាប់សំខាន់ ឬអាចនិយាយបញ្ច្រាសថាបើគ្មាន "បាយបិណ្ឌ" ប្រហែលក៏គ្មានពិធី "ភ្ជុំបិណ្ឌ" ដែរ។[4] បុរាណលោកពន្យល់ថា "បិណ្ឌ" ក្លាយពីពាក្យបាលីដែលប្រែថា "ដុំបាយ"។[5] ដុំបាយនេះ គេតែងចម្អិនពីអង្ករដំណើប ផ្សំនឹងសណ្ដែក ល្ង ខ្ទិះដូង ឬគ្រឿងដទៃទៀតតាមទម្លាប់ប្លែកគ្នាខ្លះ ហើយខ្លះមានលម្អដោយផ្កាភ្ញី ចំណិតផ្លែឈើ នំចំណី ប្រាក់ និងទៀនធូបផង។ ទម្លាប់ប្រកាន់មករបស់ស្រុកខ្លះ តែងទៅរៀបចំធ្វើបាយបិណ្ឌ ឬហៅថាពូតបាយបិណ្ឌ ឬចាប់បាយបិណ្ឌនៅវត្តតាមវេនប្រចាំភូមិ (រូបលេខ៣)។ ប៉ុន្តែអ្នកស្រុកខ្លះក៏តែងរៀបចំបាយបិណ្ឌនៅផ្ទះទីទៃៗរៀងខ្លួននៅវេលាព្រលប់ ឬវេលាទៀបភ្លឺ ទើបយកទៅឧទ្ទិសកុសល និងបោះនៅវត្ត (រូបលេខ៤)។ ទោះបីយ៉ាងណា បុរាណលោកពន្យល់ថាពេលពូតត្រូវសូត្រថា "ខ្ញុំសូមចាប់បាយបិណ្ឌ មធុបាយាស ព្រះពុទ្ធបានត្រាស់ ពោធិសត្វផង ផ្ដាំទៅតាកឹង ឱ្យចាប់ឆ្កែចង សុំផ្លូវទៅផង យកបាយទៅជូនដូនតា" ឬអ្នកខ្លះសូត្រថា "អុជធូប១ដើមកន្ទះ ព្រះពុទ្ធបានត្រាស់ពោធិកន្ទង ត្រាប់ទៅតាកឹង(បរិវាររបស់ព្រះយមរាជ) ឱ្យចាប់ឆ្កែចង(សត្វរបស់ព្រះយមរាជ) សុំផ្លូវទៅផង យកចង្ហាន់ថ្វាយមាតាបិតា"។[6] ប៉ុន្តែលោកអាចារ្យខ្លះថាពេលពូតបាយបិណ្ឌត្រូវសូត្រ "ឧកាស ឥមំ អាហារ បិណ្ឌបាតំ អហំបូជាមិ។ ទុតិយម្បិ ឥមំ អាហារ

[4] រណ្ដាប់ផ្សេងទៀតក្រៅពីបាយបិណ្ឌ គឺមានបាយចង្ហាន់ព្រះ បាយបត្តបូរ បាយប៉ារ៉ា ។ល។

[5] ពេជ្រ សល់, ១៩៦៦, ទំ.៤៩

[6] អាំង ជូលាន និង ស៊ីយ៉ុន សុភារិទ្ធ ២០១៥: ៦៨-៧១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បិណ្ឌបាតំ អហំបូជាមិ។ តតិយម្បិ ឥមំ អាហារ បិណ្ឌបាតំ អហំបូជាមិ” ហើយពេលបោះបាយបិណ្ឌត្រូវសូត្រថា “សព្វេ សត្តា អាហារបិណ្ឌបាតំ ផល្វា ផលំ ភវន្តុ”។

តាំងពីដើមរៀងមកដូនតាខ្មែរតែងប្រារព្ធពិធីភ្ជុំបិណ្ឌរយៈពេល១៥ថ្ងៃគឺពីថ្ងៃ១រោច ដល់ថ្ងៃ១៥រោច ខែភទ្របទ។ បើចែកលម្អិត ពីថ្ងៃ១រោច ដល់ថ្ងៃ១៤រោច គេហៅថាថ្ងៃកាន់បិណ្ឌ ឬថ្ងៃដាក់បិណ្ឌ ហើយនៅថ្ងៃ១៥រោច ហៅថាថ្ងៃភ្ជុំបិណ្ឌ ឬភ្ជុំធំ។ តាមទម្លាប់ស្រុកខ្លះ ភូមិនីមួយៗចុះដើរវត្ត ត្រូវទទួលកាន់បិណ្ឌតាមវេន ហើយចាត់ចែងចង្ហាន់ និងទេយ្យទានព្រះសង្ឃផង។ បើនៅតំបន់អង្គរ ក្នុងថ្ងៃកាន់បិណ្ឌនីមួយៗ គេតែងកិច្ចផ្សេងៗទៀតដូចជា ពេលល្ងាចក្រុងពាលី បួងសួងព្រះយមរាជ សែនដូនតា ព្រះសង្ឃចម្រើនព្រះបរិត្ត និង ចាប់បាយបិណ្ឌ (វត្តខ្លះចាប់បាយបិណ្ឌពីព្រលប់ ឬវត្តខ្លះធ្វើទៀបភ្លឺ) (រូបលេខ៥-៦)។





រូបលេខ៣-៤ ការរៀបចំបាយបិណ្ឌដោយរបៀបផ្សេងៗគ្នារបស់អ្នកស្រុក



រូបលេខ៥ កិច្ចសែនដូនតានៅវត្តស្វាតរំដៃ (ស្រុកអង្គរធំ ខេត្តសៀមរាប)



រូបលេខ៦ កិច្ចចម្រើនព្រះបរិត្តកាន់បិណ្ឌវត្តស្រែជា (ស្រុកជងទង់ ខេត្តកំពត)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក្នុងគំនិតអ្នកស្រាវជ្រាវ បាយបិណ្ឌអាចបកស្រាយបានវែងឆ្ងាយក្នុងបរិបទវប្បធម៌ខ្មែរ។ គេជឿថាការបោះបាយបិណ្ឌ មិនមែនក្នុងន័យបោះដើម្បីឱ្យពពួកប្រេត ដែលកំពុងស្រេកឃ្លានទាំងនោះបានទទួលទានចំអែតក្រពះទេ។ ត្រង់ចំណុចនេះ គេអាចពិចារណាពាក្យថា "បោះ" នៅក្នុងពាក្យបោះបាយបិណ្ឌនោះបាន ដ្បិតបោះមានន័យថាចោលទៅឱ្យឆ្ងាយ គឺឱ្យដល់ពពួកប្រេត ព្រោះគេជឿថាជំពូកប្រេតខ្លះខ្លាចពន្លឺ មិនហ៊ានមកក្បែរមនុស្ស ឬមិនហ៊ានចូលបរិវេណវត្តផង (រូបលេខ២៧-៨)។ លើសពីនេះមានការពន្យល់ថា បាយបិណ្ឌពូតពីអង្ករដំណើប ចំនួន១៩ពំនូត ជាតំណាងឱ្យរូបកាយដែលអាចឱ្យព្រលឹងរបស់អ្នកស្លាប់ អាចមកចាប់យករូបកាយបាន ហើយក៏អាចវិលមកកើតជាមនុស្សវិញ។ តាមទំនៀមខ្មែរជឿថាមនុស្សគ្រប់រូប មានធាតុពីរសំខាន់គឺ នាម(ព្រលឹង) និងរូប(រាងកាយ)។ នៅពេលមនុស្សស្លាប់ទៅនៅសល់តែនាម គឺព្រលឹង រីឯរូបបានរលាយបាត់ទៅហើយ។ ដោយសារហេតុផលនេះ គេជឿថា ដើម្បីឱ្យអ្នកស្លាប់អាចវិលមកកើតជាមនុស្សវិញបាន ទាល់តែធ្វើឱ្យនាមនិងរូបបានភ្ជាប់គ្នាឡើងវិញ។[7] មិនតែប៉ុណ្ណោះ បើគេសង្កេតឱ្យដិតដល់ នៅពេលបោះបាយបិណ្ឌ អ្នកស្រុកខ្លះថែមទាំងកាត់ក្រដាសដោតលើបាយបិណ្ឌមានសណ្ឋានដូចតួខ្លួនមនុស្ស (រូបលេខ២៩)។



*រូបលេខ២៧-៩ កន្លែងបោះបាយបិណ្ឌតាមជំនឿអ្នកស្រុកដូចជា ក្រៅបរិវេណវត្ត ចេតិយ ឬគល់ឈើ*

[7] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (ផ្សាយ ២០ កញ្ញា ២០២២) លើតំណ https://web.facebook.com/share/p/14q1f8kKudn/

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែកបើតាម "សាស្ត្រាអានិសង្សបិណ្ឌ" លោកថាចាប់ពីថ្ងៃ១ រោច ខែភទ្របទ មានប្រេតជាញាតិមកដោយក្តីទុក្ខសោក ខ្លះទុំនៅជើងជណ្តើរ ខ្លះនៅមាត់ទ្វារ ខ្លះនៅលើធ្នឹម ប្រមេផ្ទះ ខ្លះនៅដើមឈើ ខ្លះនៅផ្លូវច្រកល្ហក រកអាហារបរិភោគ។ ដូច្នោះបើនរណាបានរៀបរណ្តាប់បាយបិណ្ឌ និងបាយបត្តបូរ ថ្វាយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហៅថាបានធ្វើបុណ្យចម្រើនជូនទៅម្តាយឪពុកញាតិទាំងឡាយនោះ។ មិនប៉ុណ្ណោះសោត លោកឱ្យសមាទានសីល ស្តាប់ព្រះធម៌ទេសនាកុំឱ្យប្រមាទប្រហែសឡើយ ហើយចម្រើនមេត្តាភាវនាជូនផលានិសង្សទៅអស់ញាតិមិត្តសម្លាញ់ផងទាំងឡាយ ទើបនឹងបានរួចចេញអំពីទុក្ខភ័យទាំងពួងបានទៅសោយសម្បត្តិសួគ៌។ នាកាលភ្ជុំបិណ្ឌនោះដែរឱ្យរៀបអាស្នា ហើយចងនូវពិតានផង ប្រដាប់បូជានូវផ្លែឈើ ដើមឈើ ប្រដាប់នូវគ្រឿង ឱជារស គន្ធពិដោរ យកនូវបាយបិណ្ឌ បាយបត្តបូរ ភ្ញីផ្កាទាំងឡាយមកសំណាក់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដ៏ជាស្រែបុណ្យនោះមិញ វិញាតិផងទាំងឡាយក៏សិងមកសព្វទិសទីទៃៗ។ រណ្តាប់ទាំងនោះត្រូវរៀបឱ្យល្អនៅល្វែងកណ្តាលប្រមាណ១ហត្ថ ហើយទើបយកគ្រឿងត្រីសាច់ចេកអំពៅមកបូជាស្មាលានូវទោសកន្ទង់ទៅ។[8] ប្រហែលប្រការនេះហើយ ទើបខ្មែរជឿថាការធ្វើនូវកុសលវដ្តភ្ជុំបិណ្ឌ គឺឧទ្ទិសដល់បុព្វការីឱ្យបានទទួលកុសល ម្ហូបចំណីផ្សេងៗ ហើយមានទំនៀមសែនដូនតានៅតាមផ្ទះ និងជូនដូនតាក្នុងថ្ងៃបញ្ចប់ភ្ជុំបិណ្ឌ (១០-១១)។




រូបលេខ១០-១១ កិច្ចសែនដូនតា និងជូនដូនតាក្នុងថ្ងៃបញ្ចប់ភ្ជុំបិណ្ឌ

[8] សូមអាន៖ សាស្ត្រាអានិសង្សបិណ្ឌ (ចុះលេងបញ្ជីសារពើភណ្ឌ FEMC301)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*អត្ថបទ៖ ប្រវត្តិជំនឿ និងអានិសង្សបិណ្ឌ*

ជារួមពិធីភ្ជុំបិណ្ឌដែលខ្មែរជឿតមក គឺជាប្រពៃណីដ៏យូរលង់ ប្រារព្ធឧទ្ទិសកុសលដល់បុព្វការីជន ហើយអ្នកស្រាវជ្រាវយល់ថាទទួលឥទ្ធិពលពិធីស្រាទ្ធក្នុងវប្បធម៌ឥណ្ឌា ដែលមានកស្តុតាងសិលាចារឹក និងចម្លាក់។ ការប្រារព្ធពិធីរយៈពេល១៥ថ្ងៃ នៅក្នុងខែភទ្របទ ដោយមានបោះបាយបិណ្ឌ គឺតំណាងឱ្យការភ្ជាប់នាមនិងរូប(ព្រលឹង និងខ្លួន)ឱ្យពពួកប្រេតទៅយកកំណើតថ្មី។ ការសមាទានសីល ស្តាប់ធម៌ទេសនា និងកិច្ចសែនដូនតា មិនត្រឹមតែបង្ហាញពីជំនឿលើការរំដោះទុក្ខទោស និងឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធជីដូនជីតាទេ តែថែមទាំងឆ្លុះបញ្ចាំងពីជំនឿអានិសង្ស និងតម្លៃកតញ្ញូធម៌ដ៏ជ្រាលជ្រៅរបស់អ្នករស់រលឹកដល់ញាតិសន្តានដែលចែកស្ថានទៅ៕

## ឯកសារយោង

ពេជ្រ សល់
១៩៦៦, *ពិធីប្រចាំខែដប់ពីរខែ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

វង់ សុធារ៉ា
២០១២, *សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល*, នគរវត្ត, ភ្នំពេញ

អាំង ជូលាន និង ស៊ីយ៉ុន សុភារិទ្ធ
២០១៥, "ពាក្យសូត្រចាប់បាយបិណ្ឌ", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១០, ទំ.៦៨-៧១, យសោធរ, ភ្នំពេញ

ឱម ណាត្រី
(ឆ្នាំ?), *នរកថា*, បណ្ណាគារត្រៃរតន៍, ភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត